# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## សុន្ទរកថាស្វាគមន៍

**ឯកឧត្តម ងី ច័ន្ទផល រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធាន**
**ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ**
**ថ្លែងក្នុងឱកាសអបអរសាទរ ទិវាជាតិអាហារូបត្ថម្ភ លើកទី៣**
**(៦ វិច្ឆិកា ២០១៤-៦ វិច្ឆិកា ២០១៦)**
**ក្រោមប្រធានបទ**
**"អនាម័យនិងអាហារូបត្ថម្ភល្អ ជួយឲ្យកុមារលូតលាស់ល្អ"**

សាលមហោស្រពចតុមុខ, ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១៦

*********

- សូមគោរព **ឯកឧត្តម យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍ វិស័យកសិកម្ម និងជនបទ
- លោកស្រី Polly Dunford នាយិកាបេសកកម្មទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិនៅកម្ពុជា USAID តំណាងឲ្យប្រទេសអ្នកផ្តល់ជំនួយ
- លោកស្រី Debora Comini អ្នកតំណាងប្រចាំប្រទេសកម្ពុជាអង្គការ UNICEF តំណាងឲ្យភ្នាក់ងារអង្គការសហប្រជាជាតិ
- លោក Keith Porter នាយកប្រតិបត្តិអង្គការ ហេលែន ខេលឺ អន្តរជាតិ ប្រចាំកម្ពុជា តំណាងឲ្យអង្គការសង្គមស៊ីវិល
- ឯកឧត្តម លោកជំទាវ សមាជិក សមាជិកានៃរាជរដ្ឋាភិបាលកម្ពុជា

- ឯកឧត្តម លោកជំទាវ ប្រធានអង្គការដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងវិស័យឯកជននានា
- ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីជាភ្ញៀវកិត្តិយសជាតិ អន្តរជាតិ ប្អូនៗនិស្សិត យុវជន និងសមាជិក សមាជិកានៃអង្គពិធីទាំងមូលជាទីមេត្រី !

ថ្ងៃនេះ គឺជាឱកាសដ៏មហានក្ខត្តឫក្ស និងជាទិវាប្រកបដោយសេចក្តីរំភើបរីករាយយ៉ាងក្រៃលែង ដែលក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ បានសហការជាមួយ ក្រសួង ស្ថាប័នពាក់ពន្ធ័ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និង ក្រុមហ៊ុនទូរសព្ទ័នានា ប្រារព្ធខួប **ទិវាជាតិអាហារូបត្ថម្ភ លើកទី៣** ថ្ងៃទី៦ខែវិច្ឆិកា ក្រោមប្រធានបទ "**អនាម័យនិងអាហារូបត្ថម្ភល្អ ជួយឲ្យកុមារលូតលាស់ល្អ**" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**ឯកឧត្តមយឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ។

ឆ្នាំនេះជាឆ្នាំទី៣ហើយ ដែលរាជរដ្ឋាភិបាល បានប្រារព្ធទិវាជាតិអាហារូបត្ថម្ភ ឆ្លើយតបទៅនឹងការប្រកាសរបស់ពិភពលោកដែលបានបញ្ជាក់ថាសន្តិសុខស្បៀង និងអាហារូបត្ថម្ភត្រូវបានពិភពលោកទទួលស្គាល់ និងចាត់ទុកជាសិទ្ធិមូលដ្ឋានរបស់បុគ្គលម្នាក់ៗ ដែលស្ថិតក្រោមសេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្ស និងសិទ្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច-សង្គម និងវប្បធម៌ ដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័ន។ ទិវាជាតិអាហារូបត្ថម្ភលើកទី១ បានប្រារព្ធនៅថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១៤ ក្រោមប្រធានបទ "**អាហារូបត្ថម្ភល្អដើម្បីជីវិតរស់នៅកាន់តែប្រសើរ**" និងទិវាជាតិអាហារូបត្ថម្ភលើកទី២ ក្រោមប្រធានបទ"**ការបំបៅកូនដោយទឹកដោះម្តាយ គឺជាការវិនិយោគដ៏ប្រសើរបំផុតសម្រាប់ជីវិតកូនអ្នក**" បានប្រារព្ធនៅថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១៥។

ស្ថិតក្នុងបរិយាកាសដ៏មហោឡារិកនេះ ជំនួសមុខឲ្យអង្គពិធីទាំងមូល យើងខ្ញុំមានកិត្តិយសសូមស្វាគមន៍ដ៏ខ្ពង់ខ្ពស់និងកក់ក្តៅបំផុត និងសូមគោរពថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះវត្តមានដ៏ឧត្តុងឧត្តមរបស់ **ឯកឧត្តម យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍ វិស័យកសិកម្មនិងជនបទ ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ-អន្តរជាតិ មន្ត្រីរាជការ លោកគ្រូ-អ្នកគ្រូ សិស្សានុសិស្ស ដែលបានចំណាយពេលវេលាដ៏មានតម្លៃនិងមមាញឹក អញ្ជើញចូលរួមក្នុងអង្គពីធីដ៏មានសារៈសំខាន់ នាពេលនេះ។

ជំនួសមុខឲ្យអង្គពិធីទាំងមូល ខ្ញុំសូមការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ដើម្បីថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ក្រសួងស្ថាប័នពាក់ពន្ធ័ អង្គការ USAID,UNICEF, FAO,WFP, GIZ និងបណ្តាញអង្គការសង្គមស៊ីវិលដែលដឹកនាំដោយអង្គការ Helen Keller International, រួមមានអង្គការ Save the Children, Plan International, Medical Team International, Action Against Hunger, Malteser International, Samaritan's Purse, ដែលបានសហការនិងឧបត្ថម្ភដល់ ***ទិវាជាតិអាហារូបត្ថម្ភ លើកទី៣*** នេះ។ ជាពិសេស ខ្ញុំបាទសូមថ្លែងអំណរគុណ ដល់ក្រុមហ៊ុនទូរសព្ទ័ Mobitel, ក្រុមហ៊ុន MetFone និងក្រុមហ៊ុន Smart ដែលបានជួយផ្សព្វផ្សាយ តាមរយៈការបញ្ជូនសារទៅកាន់ទូរសព្ទ័ដៃរបស់អតិថិជនរបស់ខ្លួននៅទូទាំងប្រទេសនូវពាក្យស្លោកសំខាន់ៗ របស់ទិវាជាតិអាហារូបត្ថម្ភឲ្យប្រជាជនបានយល់ដឹងអំពីសារៈសំខាន់និងអត្ថប្រយោជន៍នៃទឹកស្អាត អនាម័យ និងអាហារូបត្ថម្ភ នៅប្រទេសកម្ពុជា ។ ពាក្យស្លោកទាំងនោះរួមមាន៖

1. សូមលាងសម្អាតដៃរបស់អ្នកជាមួយសាប៊ូ មុននឹងផ្តល់អាហារដល់កូនរបស់អ្នក
2. បរិភោគអាហារចម្រុះមុខ និងសំបូរជីវជាតិ ដើម្បីឱ្យមានសុខភាពល្អ
3. ប្រើប្រាស់បង្គន់អនាម័យជាប្រចាំដើម្បីកាត់បន្ថយភាពក្រិសក្រិន

- **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ជាទីគោរព**!
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ-អន្តរជាតិ ជាទីមេត្រី**!

ដើម្បីឲ្យអង្គពិធីទាំងមូលយល់ជ្រាបច្បាស់ពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ក្នុងការលើកកម្ពស់អាហារូបត្ថម្ភ ខ្ញុំបាទសូមអានសារលិខិត **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ថ្លែងក្នុងឱកាសទិវាជាតិអាហារូបត្ថម្ភលើកទី៣ ថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១៦ ក្រោមប្រធានបទ "**អនាម័យនិងអាហារូបត្ថម្ភល្អ ជួយឲ្យកុមារលូតលាស់ល្អ**" ដែលមានខ្លឹមសារទាំងស្រុងដូចតទៅ៖

# (អានសារសម្តេច)